# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៤៧/១៥ ក.អ.ជ.ប្រក

ថ្ងៃ ចន្ទ ៩កើត ខែភទ្របទ ឆ្នាំ មមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា គ.ស. ២០១៥

## ប្រកាស

## ស្តីពី

## បង្កើតក្រុមការងារអនុវត្តគម្រោង ការអភិវឌ្ឍន៍សហគមន៍ជនបទចម្រុះធន់នឹងការប្រែប្រួលអាកាសធាតុ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.**- បង្កើតអង្គភាពសម្របសម្រួល និងអនុវត្តគម្រោងអភិវឌ្ឍន៍សហគមន៍ជនបទចម្រុះធន់នឹងការប្រែប្រួលអាកាសធាតុដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | លោក **ទាង ឆាយហៀង** | នាយកគម្រោង |
| ២. | លោក **ទូច ស៊ីផាត** | ប្រធានគ្រប់គ្រងគម្រោង |
| ៣. | លោកបណ្ឌិត **ដោត ដូម៉ា** | ទីប្រឹក្សាបច្ចេកទេសគម្រោង |
| ៤. | លោក **ទឹន ហ្វេសោល** | មន្ត្រីទទួលបន្ទុកផ្នែកសាងសមត្ថភាពសហគមន៍ និងផ្សព្វផ្សាយ |
| ៥. | លោក **ស្រ៊ន់ ពិធូ** | មន្ត្រីទទួលបន្ទុកផ្នែកលទ្ធកម្ម |
| ៦. | លោក **សេង អ៊ីមហ៊ីរ** | មន្ត្រីទទួលបន្ទុកផ្នែកទឹកស្អាត |

| | | |
|---|---|---|
| ៧. | លោកស្រី គង់សាលី | មន្ត្រីទទួលបន្ទុកផ្នែកអនាម័យ |
| ៨. | លោកស្រី ថាង ឌីណា | មន្ត្រីទទួលបន្ទុកផ្នែកតាមដាន និងវាយតម្លៃ |
| ៩. | លោកស្រី ទិត្យ សុភ័ក្រ្ត | មន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ |
| ១០. | លោក សាន វិសាល | មន្ត្រីទទួលបន្ទុកផ្នែកបច្ចេកទេសផ្លូវជនបទ |
| ១១. | លោក តាន់ វាសនា | មន្ត្រីថ្នាក់ខេត្តទទួលបន្ទុកផ្នែកទឹកស្អាត |
| ១២. | លោក ត្នង តា | មន្ត្រីថ្នាក់ខេត្តទទួលបន្ទុកផ្នែកបច្ចេកទេសផ្លូវជនបទ |
| ១៣. | លោក ចាន់ សង្ហា | មន្ត្រីថ្នាក់ខេត្តទទួលបន្ទុកផ្នែកអនាម័យ |
| ១៤. | លោក ស៊ីន វុទ្ធា | មន្ត្រីថ្នាក់ខេត្តទទួលបន្ទុកផ្នែកអភិវឌ្ឍន៍សហគមន៍ |

**ប្រការ ២.-** មន្ត្រីរាជការដូចមានក្នុងប្រការ ១ មានភារកិច្ចទទួលខុសត្រូវសម្របសម្រួល និងដឹកនាំការងារអនុវត្តគម្រោងអភិវឌ្ឍន៍សហគមន៍ជនបទចម្រុះធន់នឹងការប្រែប្រួលអាកាសធាតុ ក្រោមហិរញ្ញប្បទានរបស់សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ (CCCA) ឱ្យសម្រេចជោគជ័យ។

**ប្រការ ៣.-** ប្រគល់ភារកិច្ចជូន ឯកឧត្តម លី ស៊ីមអ៊ាម អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ជាអ្នកសម្របសម្រួលគម្រោងនេះ។

**ប្រការ ៤.-** សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ គ្រប់ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ និងសាមីខ្លួន ដូចមានក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជា សុផារ៉ា

<u>ចម្លងជូន÷</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ

  "<u>ដើម្បីជូនជ្រាប</u>"
- ដូចប្រការ ១, ៣ និង ៥

  "<u>ដើម្បីអនុវត្ត</u>"
- ឯកសារ-កាលប្បវត្តិ